ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១៧ សសរ

**សេចក្តីសម្រេច**
**ស្តីពី**
**ការបង្កើតគណៈកម្មការសម្រាប់កំណត់សមត្ថកិច្ចគ្រប់គ្រង និងការប្រើប្រាស់ប្រេកង់ស៍ ៧០០ MHz**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៧ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីទូរគមនាគមន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នា១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ៣៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

**ស ម្រេ ច**

**ប្រការ១.**_

ត្រូវបានបង្កើតគណៈកម្មការដើម្បីសិក្សាស្តីពីស្ថានភាពបច្ចុប្បន្ននៃការគ្រប់គ្រង ការបែងចែក និងការប្រើប្រាស់ប្រេកង់ស៍ ៧០០ MHz សម្រាប់កំណត់សមត្ថកិច្ចគ្រប់គ្រង និងការប្រើប្រាស់ប្រេកង់ស៍ ៧០០ MHz នេះ។

**ប្រការ២.**_

គណៈកម្មការមានសមាសភាពដូចខាងក្រោមៈ

| | | |
|---|---|---|
| ១. ឯកឧត្តម **ត្រាំ អ៊ីវតឹក** | រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | ប្រធាន |
| ២. ឯកឧត្តម **សារ៉ាត់ ខាន់** | រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ៣. ឯកឧត្តម **សុខ ពុទ្ធិវុធ** | អនុរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ៤. ឯកឧត្តម **វង្វៀង ស៊ីនលី** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៥. ឯកឧត្តម **ជា មានិត** | អនុរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |

www.pheakdeylaw.com

៦. ឯកឧត្តម **ញឹក កោសល្យវិទូ** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៃទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

៧. ឯកឧត្តម **ផុស សុវណ្ណ** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា និងជាអគ្គនាយកនៃអគ្គនាយកដ្ឋានព័ត៌មាន និងសោតទស្សន៍ នៃក្រសួងព័ត៌មាន សមាជិក ។

**ប្រការ៣.**_

គណៈកម្មការនេះមានតួនាទី និងភារកិច្ចសំខាន់ៗដូចខាងក្រោម៖

- ដឹកនាំនិងសម្របសម្រួលលើការងាររៀបចំការសិក្សាស្តីពីស្ថានភាពបច្ចុប្បន្ននៃការគ្រប់គ្រង ការបែងចែក និងការប្រើប្រាស់ហ្វ្រេកង់ស៍ ៧០០ MHz ឲ្យទទួលបានជោគជ័យ
- ប្រមូលធាតុចូលទាំងអស់ពាក់ព័ន្ធនឹងការបែងចែក និងការប្រើប្រាស់ហ្វ្រេកង់ស៍ ៧០០ MHz ពីក្រសួង ស្ថាប័នពាក់ព័ន្ធនានា
- ដឹកនាំរៀបចំសិក្ខាសាលាថ្នាក់ជាតិ ដោយសហការជាមួយនឹងសហភាពទូរគមនាគមន៍អន្តរជាតិ ដៃគូសន្ទនា និងដៃគូអភិវឌ្ឍពាក់ព័ន្ធ ព្រមទាំងវិស័យឯកជន ដើម្បីជានាអនុលោមភាពរបស់កម្ពុជាជាមួយនឹងសុខដុមនីយកម្មតំបន់និងពិភពលោក លើសមត្ថកិច្ចគ្រប់គ្រងនិងការប្រើប្រាស់ហ្វ្រេកង់ស៍ ៧០០ MH និងដើម្បីទទួលបាននូវការចូលរួមចែករំលែកអំពីឧត្តមានុវត្តន៍លើសមត្ថកិច្ចគ្រប់គ្រង និងការប្រើប្រាស់ហ្វ្រេកង់ស៍ ៧០០ MHz នៅក្នុងតំបន់ និងពិភពលោក
- ដឹកនាំរៀបចំនិងកំណត់សមត្ថកិច្ចគ្រប់គ្រង និងការប្រើប្រាស់ហ្វ្រេកង់ស៍ ៧០០ MHz
- គណៈកម្មការអាចសហការ ឬស្នើឲ្យមានកិច្ចសហការពីក្រសួង ស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍតាមតម្រូវការជាក់ស្តែង
- រៀបចំនិងដាក់ជូនលទ្ធផលស្តីពីការសិក្សានិងការកំណត់សមត្ថកិច្ច និងការប្រើប្រាស់ហ្វ្រេកង់ស៍ ៧០០ MHz ជូនប្រមុខរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច ។ សេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលើកិច្ចការនេះនឹងត្រូវបានប្រើប្រាស់ដើម្បីធ្វើជាមូលដ្ឋានបន្ថែមនៃការរៀបចំសេចក្តីព្រាងច្បាប់គមនាគមន៍វិទ្យុ ។

**ប្រការ៤.**_

គណៈកម្មការមានសិទ្ធិអញ្ជើញមន្ត្រីជំនាញជាតិ និងអន្តរជាតិមកចូលរួមផ្តល់យោបល់បន្ថែមលើប្រធានបទនេះ ហើយអាចចាត់តាំងក្រុមការងារតាមការចាំបាច់ ។

**ប្រការ៥.**_

គណៈកម្មការមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ។

**ប្រការ៦.**_

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៧.**_

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ រដ្ឋមន្ត្រីក្រសួងព័ត៌មាន រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសមាសភាពដូចមានចែងក្នុងប្រការ២ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ថ្ងៃពុធ ១៣ កើត ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស.២៥៦១

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៧
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

www.pheakdeylaw.com